# បើមានធម៌អ្នកនឹងបានសុខ

*ចូរអ្នកតាំងនៅក្នុងធម្មៈ វិរិយៈព្យាយាមឲ្យជាប់លាប់*
*តស៊ូអត់ធន់ទើបបានជួប ឈ្មោះល្អនឹងទ្រព្យគាប់ប្រសើរ ។*
*ទុកជាគំរូកូនចៅក្រោយ ពេលគេដឹងហើយនឹងបានដើរ*
*តាមគំរូល្អដែលយើងធ្វើ សាងទុកខាងលើជាច្បាប់ក្រម ។*
*ចំណេះទាំងឡាយកើតព្រោះរៀន ចំណែកធនធានកើតព្រោះខំ*
*កើតពីញើសឈាមដែលស៊ូទ្រាំ ព្យាយាមសន្សំទាំងយប់ថ្ងៃ ។*
*ចូរអ្នកញ៉ាំងសុខឲ្យកើតឡើង សុខនឹងដំកើងឲ្យផុតភ័យ*
*សុខនឹងជួយមនុស្សដែលឃ្លាតឆ្ងាយ ចាកក្តីខ្វល់ខ្វាយកាមទាំងពួង ។*
*ទោះបីមានភេទជាបព្វជិត បើសិនមានចិត្តជាប់ហែងហួង*
*ជាប់កាមារម្មណ៍ណែនក្នុងទ្រូង ជាប់ទ្រព្យលលួងលកលៃលោភ។*
*ជាប់ចិត្តឆេវឆាវក្រោធខឹងងាយ រវើរវាយទាំងថ្ងៃយប់*
*ជាប់នឹងបញ្ចខន្ធមិនឈរឈប់ នោះលោកនឹងជួបក្តីទុក្ខា ។*
*ទោះបីមានភេទជាគ្រហស្ថ បើមានចិត្តស្មោះលះកាមា*
*លះនូវអារម្មណ៍នាំទុក្ខា លះចិត្តឫស្យាផុតកង្វល់ ។*
*តាំងចិត្តប្រព្រឹត្តប្រតិបត្តិ តាំងចិត្តកំចាត់ក្តីខ្វាយខ្វល់*
*ហើយខំសន្សំតែកុសល នោះនឹងបានដល់ក្តីសុខហោង។៕*